ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៦៣៥/៣០៤ កសក-ជន.ជក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៨

# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ជម្រាបមក

## ឯកឧត្តមអភិបាលខេត្ត និងជាប្រធានអនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំ

**កម្មវត្ថុ:** ករណីសំណើសុំសម្បទានដីសេដ្ឋកិច្ច របស់ក្រុមហ៊ុន **ជីង គ័រ អាហ៍រ័ណ នីហរ័ណ** (CHING KOR IMPORT EXPORT Co.,Ltd ) លើផ្ទៃដីចំនួន ១.០៩១ ហិកតា សម្រាប់វិនិយោគដាំដំណាំស្រូវ ដែលមានទីតាំងស្ថិតនៅតំបន់វាលក្រោម ក្នុងភូមិសាស្ត្រឃុំកកោះ និងឃុំព្នៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

**យោង:** លិខិតលេខ ៦១ ស.ណ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ របស់ សាលាខេត្តកំពង់ធំ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអភិបាលខេត្តជ្រាបថា: តាមការពិនិត្យលើសំណើសុំសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជីង គ័រ អាហ៍រ័ណ នីហរ័ណ (CHING KOR IMPORT EXPORT Co., Ltd ) លើផ្ទៃដីចំនួន ១.០៩១ ហិកតា សម្រាប់វិនិយោគដាំដំណាំស្រូវ ដែលមានទីតាំងស្ថិតនៅតំបន់វាលក្រោម ក្នុងភូមិសាស្ត្រឃុំកកោះ និងឃុំព្នៅ ស្រុកសន្ទុក ខេត្តកំពង់ធំនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឯកភាពតាមសំណើរបស់ឯកឧត្តមអភិបាលខេត្ត ដោយផ្តល់ទិដ្ឋាការជូនក្រុមហ៊ុន ជីង គ័រ អាហ៍រ័ណ នីហរ័ណ (CHING KOR IMPORT EXPORT Co., Ltd ) ធ្វើវិនិយោគលើផ្ទៃដីចំនួន ៣៨៧ ហិកតា សម្រាប់វិនិយោគតែដំណាំស្រូវ ។ បន្ទាប់ពីទទួលបានទិដ្ឋាការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយ អាជ្ញាធរខេត្តកំពង់ធំ ត្រូវសហការជាមួយជំនាញពាក់ព័ន្ធនៅមូលដ្ឋាន ពិសេសរដ្ឋបាលជលផលមូលដ្ឋាន ដើម្បីចុះពិនិត្យកាត់ចេញផ្ទៃដីពាក់ព័ន្ធសហគមន៍ ផ្ទៃដីបឹងបួរ និងផ្ទៃដីឡូតិ៍នេសាទលេខ ៧ ដែលត្រូវរក្សាទុក និងត្រូវរៀបចំអោយក្រុមហ៊ុនបំពេញបែបបទ តាមស្មារតីអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច មុននឹងចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ។ ក្រុមហ៊ុនត្រូវសហការជាមួយរដ្ឋបាលជលផល ដើម្បីរៀបចំផែនការ វិនិយោគអោយច្បាស់លាស់ ដោយធានាថា មិនមានសកម្មភាព ឬហេដ្ឋារចនាសម្ព័ន្ធអ្វី ដែលធ្វើអោយរំខានដល់ចរាចរការពងកូន នៃមច្ឆជាតិ និងទីតាំងមិនស្ថិតក្នុងប្រព័ន្ធទំនប់ប្រឡាយ ដែលរាជរដ្ឋាភិបាលផ្អាក ដើម្បីធ្វើការសិក្សា ។ ក្នុងកិច្ចសន្យាត្រូវមានចែងពីលក្ខខ័ណ្ឌ នៃការធានាអោយប្រជាជននៅក្នុងតំបន់វិនិយោគ អាចទទួលបាននូវផលប្រយោជន៍ពីគម្រោងវិនិយោគ និងលក្ខខ័ណ្ឌនៃការបង្កកគម្រោងវិនិយោគនៅតាមទីតាំងណា ដែលមានទំនាស់អំពីកម្មសិទ្ធិជាមួយប្រជាជនរហូតដល់មានការដោះស្រាយ រួចរាល់ត្រឹមត្រូវ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលខេត្តជ្រាប និងចាត់ចែងនីតិវិធានការតាមការគួរ ។

ចាន់ សារុន

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងមហាផ្ទៃ
- រដ្ឋបាលជលផល
- មន្ទីរកសិកម្មខេត្តកំពង់ធំ
- ក្រុមហ៊ុន ជីង គ័រ អាហ៍រ័ណ នីហរ័ណ (CHING KOR IMPORT EXPORT Co., Ltd )
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N. 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D. Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣)២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351 / 211 352. Fax : (855) 23-217 320